ឧប សៅ សង្ហា

# សណ្តាប់ធ្នាប់ ពិភពលោក



## មាតិការឿង


អារម្ភកថា ........................................ 1
ការវិវត្តន៍ នៃ សណ្តាប់ធ្នាប់ ពិភពលោក ........................ 6
សន្តិភាព ........................................ 16
ខណ្ឌសីមាថ្មី នៃ ពិភពលោក ........................................ 19


# សណ្តាប់ធ្នាប់ ពិភពលោក

## អារម្ភកថា

ពិភពលោក ក្រោយ ពី បញ្ចប់ សង្គ្រាម លោក ទី២ តាម ការជម្រុញចិត្ត របស់ លោក ប្រធានាធិបតី អាមេរិកាំង Roosevelt បានបង្កើត (២៤ តុលា ឆ្នាំ ១៩៤៥) អង្គការ

សហប្រជាជាតិ (អ.ស.ប.) ជំនួស សង្គម នៃ ប្រជាជាតិ (société des Nations)។ អង្គការ ថ្មី នេះ មាន គោលដៅ សំរាប់ សំរួល នូវ សហប្រតិបត្តិការ អន្តរជាតិ នៅក្រោម ច្បាប់ អន្តរជាតិ, សន្តិសុខ អន្តរជាតិ, អភិវឌ្ឍន៍ សេដ្ឋកិច្ច ការរីកចំរើន សង្គម, ការពារ សិទ្ធិមនុស្ស និង ធ្វើ អោយបាន សម្រេច នូវ សន្តិភាពនៅក្នុងពិភពលោក។ អ.ស.ប. ជាវេទី នៃ ការសន្ទនា រវាង ប្រជាជាតិ នៅក្នុង ការ គោរព គ្នា ទៅវិញ ទៅមក នូវ អធិបតេយ្យភាព នៃ ប្រជាជាតិ និមួយៗ។ ព្រលឹងស្មារតី (esprit) នៃ អ.ស.ប. នេះហើយ ដែល ជា សណ្តាប់ធ្នាប់ (ordre) នៃ ពិភពលោក។ ហើយ បន្ត បន្ទាប់ មក មាន បង្កើត អង្គការ អន្តរជាតិ សំខាន់ៗ ដើម្បី ពង្រឹក សណ្តាប់ធ្នាប់ អន្តរជាតិ ដូចយ៉ាង មូលនិធិ រូបិយវត្ថុ អន្តរជាតិ (F.M.I ou IMF) , តុលាការ ព្រហ្មទណ្ឌ អន្តរជាតិ (CPI ou ICC)។

ក្រោយពី សង្គ្រាម លោក លើកទី២ មក ពិភពលោក បែង ចែង ជា ប៉ូល ពីរះ ទី១ គឺ លោក សេរី ដែល មាន សហរដ្ឋ អាមេរិក ជា ប្រមុខ មាន ឧត្តមគតិ ពីរសំខាន់ គឺ ឈរ លើ លទ្ធិប្រជាធិបតេយ្យសេរី និង សិទ្ធិ របស់ ប្រជាពលរដ្ឋ និមួយៗ អាច សំរេច ជា ស្វ័យប្រវត្តិ លើ ជោគ វាសនា របស់ ខ្លួន។ ឧត្តមគតិ នេះហើយ ជា ពលវេគ របស់ ប្រទេសអណានិគម ទាមទារ ឯករាជ្យ និង ប្រជាពលរដ្ឋ រស់នៅ ក្រោម អំណាច សក្តិភូមិ និង អំណាច ផ្តាច់ការ

កស៊ូ ស្វែងរក សេរីភាព និង សិទ្ធិ ជា ពលរដ្ឋ ដើម្បី សម្រេច ដោយ ខ្លួនឯង លើ ជោគវាសនា របស់ ខ្លួន។ រីឯ ប៉ូល ទី២ វិញ គឺ លោក កុម្មុយនិស្ត ដែល មាន សហភាពសូវៀត រ៉ូស៊ី ជា ប្រមុខ មាន ឧត្តមគតិ បង្កើត សង្គម គ្មាន វណ្ណៈ ដោយ ប្រើ មធ្យោបាយ បដិវត្ត ដឹកនាំ ដោយ បក្សកុម្មុយនិស្ត វាយ រំលាយ សង្គម ចាស់ អោយ បាត់ សាបសូន្យ។ ប៉ូល ទាំងពីរ នេះ មាន ទំនាស់ មនោគមវិជ្ជា នឹងគ្នា នាំ បង្កើត សង្គ្រាម មួយ ដែល គេ អោយ ឈ្មោះ ថា សង្គ្រាម ត្រជាក់។ ហើយ ប៉ូល និមួយៗ នាំគ្នា បង្កើត ស្ថាប័ត មួយ ចំនួន ដើម្បី ការពារ ផែនដី (espace) ស្ថិត នៅក្រោម ឥទ្ធពល របស់ ខ្លួន ដូច នៅ អឺរ៉ុប លោក សេរី បានបង្កើត (ថ្ងៃទី ៤ មេសា ឆ្នាំ ១៩៤៩) កតិកាសញ្ញា យោធា មាន ឈ្មោះ កាត់ ថា អូតង់ ឬ ណេតូ[1] សំរាប់ ការពារ ពលក្ការ នៃ លោក កុម្មុយនិស្ត។ នៅ អាស៊ី សហរដ្ឋ អាមេរិក បាន បង្កើត (ឆ្នាំ ១៩៥៤) កតិកាសញ្ញា យោធា នៃ បណ្ដា ប្រទេស មិនមែន កុម្មុយនិស្ត នៅ អាស៊ី ភាគ អគ្នេយ៍ មួយដែរ មាន ឈ្មោះ កាត់ ថា អាសេអាន ឬ សេអាតូ[2] ដើម្បី ទប់ទល់ នឹង ការរាតទី នៃ លទ្ធិកុម្មុយនិស្ត នៅក្នុង

---

[1] L'Organisation du traité de l'Atlantique nord (OTAN ou Otan ; en anglais : North Atlantic Treaty Organization, NATO ; aussi nommé « l'Alliance », pour « Alliance atlantique »)។

[2] L'Organisation du Traité de l'Asie du Sud-Est (OTASE ou Pacte de Manille ; en anglais : Southeast Asia Treaty Organization, SEATO), mise en place en 1954, était un pacte militaire pro-occidental, regroupant des pays de l'Asie du Sud-Est non communistes.

*(note de bas de page - suite)*

ដំបន នោះ។ ចំណែក លោក កុម្មុយនិស្ត វិញ មាន បង្កើត (១៤ ឧសភា ឆ្នាំ ១៩៥៥) នៅ អឺរ៉ុប កតិកាសញ្ញា នយោបាយ សេដ្ឋកិច្ច និងយោធា មួយ មាន ឈ្មោះ កាត់ ថា កតិកាសញ្ញា វ៉ាសូវី[3]។ នៅក្នុង សង្គ្រាម ត្រជាក់ រវាង លោក សេរី នឹង លោក កុម្មុយនិស្ត នាំ អោយ ប្រទេស មួយ ចំនួន មាន ប្រទេស ឥណ្ឌូណេស៊ី, ឥណ្ឌា, កុយបា, អាហ្វ្រិក ខាងត្បូង, អៀរ៉ង់ និង អតីត ប្រទេស យូហ្គោស្លាវី មាន គំនិតផ្តួចផ្តើម បង្កើត (១៩ កក្កដា ឆ្នាំ ១៩៥៦) ប្រតិព័ន្ធ (bloc) នៃ ចលនា នៃ ប្រទេស មិនចូល ប្រតិព័ន្ធ ខាង ណា។ នៅ ថ្ងៃ ទី២៣ វិច្ឆិកា ឆ្នាំ ១៩៧១ សាធារណរដ្ឋ ចិន ប្រជាមានិត ក្លាយ ជា សមាជិក អចិន្ត្រៃយ៍ នៃ ក្រុមព្រឹក្សា សន្តិសុខ នៃ អ.ស.ប. ជំនួស ចិន អ្នកជាតិនិយម ហៅថា ចិន តៃវ៉ាន់។ ការជំនួស នេះ ជា ឆន្ទៈ របស់ សហរដ្ឋ អាមេរិក យក ចិន ជា ទំនុប បិទ ចរន្ត ទឹក សហភាព សូវៀត ហូរ ចូល ដំបន់ អាស៊ី ភាគ អគ្នេយ៍ តាម សង្គ្រាម នៅ វៀតណាម។ ចំពោះ លោក ប្រធានាធិបតី R. Nixon យុទ្ធសា

[3] Le pacte de Varsovie est une ancienne alliance militaire groupant les pays d'Europe de l'Est avec l'URSS dans un vaste ensemble économique, politique et militaire. Il est conclu le 14 mai 1955 entre la plupart des États du Bloc communiste par un traité d'amitié, de coopération et d'assistance mutuelle. Nikita Khrouchtchev, qui en fut l'artisan, l'avait conçu dans le cadre de la Guerre froide comme un contrepoids à l'Organisation du traité de l'Atlantique nord (OTAN) qui avait vu le jour en avril 1949.
Cependant, la principale raison ayant motivé la formation du pacte de Varsovie, selon l'exposé des motifs, fut l'adhésion de la République fédérale d'Allemagne « en voie de remilitarisation » au traité de l'Atlantique Nord le 9 mai 1955, rendu possible après la ratification par les pays occidentaux des Accords de Paris. L'alliance est dissoute en juillet 1991.

ស្ត្រ យក ចិន កុម្មុយនិស្ត ជា មិត្ត គឺ សំរាប់ អនុវត្ត នយោបាយ ដក កងទ័ព អាមេរិកាំង ពី វៀតណាម ដោយ យក ចិន ជា ការធានា កុំ អោយ មាន អនុភាព នៃ ល្បែង ដូមីណូ នៅ អាស៊ី អគ្នេយ៍ និង បន្ថយ ឥទ្ធិពល សហភាព សូវៀត លើ អ្នកដឹកនាំ យួន កុម្មុយនិស្ត ប្រសិន ជា វៀកណាម ខាងជើង ឈ្នះ សង្គ្រាម លើ វៀតណាម ខាងត្បូង។ យុទ្ធសាស្ត្រ នេះហើយ ដែល នាំ អោយ មាន កិច្ចព្រមព្រៀង សន្តិភាព នៅ វៀតណាម ចុះ ហត្ថលេខា នៅ ថ្ងៃ ទី ២៧ មករា ឆ្នាំ ១៩៧៣ នៅ ទីក្រុង បារីស រវាង ភាគី ពាក់ព័ន្ធ នឹង សង្គ្រាម។ កិច្ចព្រមព្រៀង សន្តិភាព នេះ ជា សញ្ញា ចំពោះ ប្រជាពលរដ្ឋ រស់នៅ ក្នុង ដំបន់ ឥណ្ឌូចិន មាន ខ្មែរ លាវ និង យួន នៃ ការបោះបង់ចោល របប សេរី ពី សំណាក់ សហរដ្ឋអាមេរិក ដែល ជា រដ្ឋាភិបាល ពេញច្បាប់ តស៊ូ ប្រឆាំង នឹង ពួក ឧទ្ទាម កុម្មុយនិស្ត មាន ឈ្មោះ ថា ខ្មែរ ក្រហម, យៀកកុង និង ប្រថេតលាវ។ សហរដ្ឋ អាមេរិក បាន បញ្ចប់ សង្គ្រាម នៅ ឥណ្ឌូចិន តែ ដំណាច់ (fin) នេះ បើកឱកាស អោយ របប កុម្មុយនិស្ត ដែល ជា អ្នកឈ្នះ នៅ ស្រុកខ្មែរ សម្លាប់ ប្រជាជនខ្មែរ ជាង ពីរ លាន ដោយ សេរី តាម គ្រប់ មធ្យោបាយ។ នេះ ជា តម្លៃ ដ៏ខ្ពស់មួយ ដែលពិភាពលោក មិនដែល ជួប ប្រទះ របស់ ប្រជាជាតិខ្មែរ ដែល មាន គោលដៅ តែមួយគត់ នៅ ក្នុង សង្គ្រាមនោះ គឺ គោលបំណង ការពារ

បូរណភាព ទឹកដី ជាតិ ពី ការរំលោភ ដាក់ស្តែង លើ ច្បាប់ អន្តរជាតិ ពី សំណាក់ កងទ័ព យួន កុម្មុយនិស្ត។ ជា ការ ចំអក ដល់ ព្រហ្មលិខិត នៃ ប្រជាពលរដ្ឋខ្មែរ ជា អ្នករង គ្រោះ ពី កងទ័ព ឈ្លានពាន យួនកុម្មុយនិស្ត នៅ ឆ្នាំ ១៩៧០ បានត្រូវ កងទ័ពនេះ វាយចូល ស្រុកខ្មែរ នៅ ឆ្នាំ ១៩៧៩ ក្នុង នាម ជា កងទ័ព រំដោះខ្មែរ ពី របបប្រល័យ ពូជសាសន៍ខ្មែរ ខ្លួនឯង នៅ ចំពោះមុខ មហាចិន ដែល ជា ពាំនឹង របស់ខ្លួន។

## ការវិវត្តន៍ នៃ សណ្តាប់ធ្នាប់ ពិភពលោក

ពិភពលោក រស់នៅ ក្នុង ចរភាព ជានិច្ច ហើយ តែងតែ ជួបប្រទះ នឹង ការគំរាម គ្រប់ បែបយ៉ាង។ ដូច បាន បញ្ជាក់ ខាងលើ រួច មក ហើយ ថា ទស្សនៈ ជា មូលដ្ឋាន នៃ សណ្តាប់ធ្នាប់ ពិភពលោក គឺ អធិបតេយ្យភាព នៃ ប្រជាជាតិ។ អធិបតេយ្យភាព គឺ ជា សិទ្ធិ ជា ប្រជាជាតិ ឯករាជ្យ និង ស្វ័យភាព។ គោលការណ៍ នេះ ជា ការការពារ នូវ ពុទ្ធសិទ្ធិ នៃ ប្រជាជាតិ និមួយៗ។ អធិបតេយ្យភាព នៃ ប្រជាជាតិ និមួយៗ មាន ប្រភព ជា ប្រវត្តិសាស្ត្រ ចេញ ពី ទ្វិព អឺរ៉ុប មាន ឈ្មោះ ថា កតិកាសញ្ញា ហ្វេសហ្វីលីយា (westphilia)[4] ដែល ជា កតិសញ្ញា មាន គោលដៅ ដើម្បី

[4] Les traités de Westphalie (ou paix de Westphalie) conclurent la guerre de Trente Ans et la guerre de Quatre-Vingts Ans le 24 octobre 1648. Ils sont à la
*(note de bas de page - suite)*

វៀរចាក សង្គ្រាម រវាង ប្រជាជាតិ នឹង ប្រជាជាតិ ដោយ គោរព ទៅវិញ ទៅមក ដល់ អធិបតេយ្យភាព នៃ ប្រជាជាតិនិមួយៗ គឺ ថា ប្រជាជាតិ មួយ មិន ត្រូវ ជ្រៀតជ្រែក ចូល ក្នុង កិច្ចការ ផ្ទៃក្នុង របស់ ប្រជាជាតិ មួយទៀត។ គោលការណ៍ នេះ គេ យក វា មក អនុវត ក្នុង នយោបាយ ការបរទេស នៅ ក្នុង ពិភពលោក រហូតមក។ តែ វា ក៍ គ្មាន ប្រសិទ្ធភាព ជា ដាច់ខាត នោះ ដែរ ព្រោះ ថា នៅ អឺរ៉ុប នៅ តែ មាន កើត មហាសង្គ្រាម ពីរលើក ដែល ជា សង្គ្រាម ពិភពលោក ដែល នាំ ឲ មនុស្ស រាប់លាន នាក់ បាត់បង់ ជីវិត។ កាបង្កើត អង្គការសហប្រជាជាតិ (អ.ស.ប.) ក្រោយ ពី សង្គ្រាម ពិភព លោក លើកទី២ គឺ នៅ ក្នុង គោលគំនិត វៀរចាក សង្គ្រាម រវាង ប្រជាជាតិ ជា សមាជិក នៅ ក្នុង មនោគតិ ហ្វេសហ្វីលីយា នោះឯង គឺ ឈរ លើ គោលការណ៍ នៃ ការគោរព អធិបតេយ្យភាព នៃ ប្រជាជាតិ និមួយៗ តែ អធិបតេយ្យភាព គ្រប់គ្រង ដោយ ធម្មនុញ្ញ នៃ អ.ស.ប. ដែល សមាជិក និមួយៗ ត្រូវ គោរព វា ជា ច្បាប់ អន្តរជាតិ។ កតព្វកិច្ច នេះ ឯង ដែល អាច ឲ អ.ស.ប. មាន លទ្ធភាព អាច ដោះស្រាយ វិបត្តិ អន្តរជាតិ

base du « système westphalien », expression utilisée à posteriori pour désigner le système international spécifique mis en place, de façon durable, par ces traités.
Catholiques et protestants ayant refusé de se rencontrer, les négociations se tinrent à partir de décembre 1644 à Münster pour les premiers et à partir de 1645 à Osnabrück pour les seconds. Cette solution qui avait été proposée par la Suède est préférée à la solution française qui suggérait Hambourg et Cologne.

ជា ច្រើន ដូចយ៉ាង ការដាក់ ទោស ដល់ ប្រជាជាតិ ណា ដែលបំពាន លើ ប្រជាជាតិ ដទៃ មាន ជា ឧទាហរណ៍ នៅ ទសវត្សរ៍ ៧០ មាន ការសម្រេចចិត្ត របស់ អ.ស.ប. ផ្តន្ទាទោស ដល់ប្រទេស វៀតណាម ដែល បាន ឈ្លានពាន តាម កម្លាំង យោធា មក លើ អធិបតេយ្យ នៃ ស្រុកខ្មែរ។ ដូចគ្នាដែរ នៅ ទសវត្សរ៍ ៩០ អ.ស.ប. បាន ផ្តន្ទាទោស ប្រទេស អៀរ៉ាក់ (Irak) ពី ការឈ្លានពាន តាម កម្លាំងទ័ព ដល់ ប្រទេស កូវ៉ែត។ បច្ចាប័ន (sanction) នៃ អ.ស.ប. ជូន ជា វិធានការ បែប និន្ទិវាសណ៍ នៃ សេដ្ឋកិច្ច ឬ ពាណិជ្ជកម្ម ជូន ជា អន្តរាគមន៍ផ្ទាល់ តាម ផ្លូវយោធា ដើម្បី ធ្វើ ការ សង្កត់ ទៅ លើ ប្រជាជាតិ មាន កំហុស នៅ ចំពោះ មុខ ច្បាប់ អន្តរជាតិ។

នៅ ក្នុង វិស័យ សិទ្ធិមនុស្ស អ.ស.ប. បាន ធ្វើ បច្ចាប័ន ដល់ របប ដឹងនាំ បែងចែក ពណ៌សម្បុរ មនុស្ស ឬ អភិវឌ្ឍន៍ ញែក រវាង ពណ៌សម្បុរ មនុស្ស នៅ ប្រទេស អាហ្វ្រិក ខាងត្បូង មាន ឈ្មោះ ថា របប អាប៉ាថេត (régime apartheid)។ និន្ទិវាសណ៍ សេដ្ឋកិច្ច ដល់ របប នោះ ជំរុញ អោយ អ្នកដឹកនាំ សុខចិត្ត បោះបង់ វា ចោល ប្តូរ មក អនុវត្ត របប លទ្ធិប្រជាធិបតេយ្យសេរី វិញ។ អន្តរាគមន៍ ផ្ទាល់ របស់ អ.ស.ប. នៅស្រុកខ្មែរ នៅ ទសវត្សរ៍ ៩០ ដើម្បី បញ្ចប់ ការត្រួតត្រា ស្រុកខ្មែរ ដោយ កងទ័ព យួន និង បញ្ចប់សង្គ្រាម។ ទង្វើ របស់ អ.ស.ប. ដែល បាន រៀបរាប់

ដូច ខាងលើ នេះ បញ្ជាក់ បង្ហាញ នូវ តួ នាទី សំខាន់ របស់ អ.ស.ប. ក្នុង ការរក ដំណោះស្រាយ នៃ វិបត្តិ រវាង ប្រជាជាតិ នឹង ប្រជាជាតិ និង សង្គ្រាម ស៊ីវិល។

គេ ដឹង ថា ចរភាព នៃ ពិភពលោក បច្ចុប្បន្ន គឺ ដំណើរ ដើរ ទៅរក ពិភពលោកូបនីយកម្ម[5] ព្រោះ គ្រប់ ព្រឹត្តិការ ណ៍ តូច ធំ ក្តី ដែល មាន កើតឡើង ពាក់ព័ន្ធ នឹង បញ្ហា មនុស្សលោក ត្រូវបាន គេ ផ្សាយ ភ្លាមៗ តាម បណ្តាញ ឯកជន ក្តី តាម បណ្តាញ ផ្លូវការ ក្តី ពេញ ពិភពលោក។ ការផ្សាយព័ត៌មាន ដោយសារ ការរីកចំរើន នៃ វិទ្យាសាស្ត្រ ព័ត៌មាន លែង មាន ព្រំដែន សំរាប់ មនុស្សជាតិ ព្រោះ ប្រជាជាតិ និមួយៗ មិន អាច រស់នៅ ឯកា បាន នោះ ឡើយ នៅ ក្នុង ពិភពលោកូបនីយកម្ម ដែល មាន បញ្ហា ធំៗ ជា ច្រើន វា ក្លាយ ជា បញ្ហារួម នៃ មនុស្សជាតិ ដូច យ៉ាង បញ្ហា សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ, បរមាណូ, ប រិស្ថាន, សុខភាព សាធារណជន, អន្តោប្រវេសន៍, ជនភាស ខ្លួន, ភេរវកម្ម, សេដ្ឋកិច្ច, ពាណិជ្ជកម្ម និង អំពើ ពុក រលួយ នៃ ពួក អ្នកដឹកនាំ។ នៅ ចំពោះមុខ បញ្ហា រួម ទាំង នេះ ដែល នាំ អោយ មាន កែប្រែ ទ្រង់ទ្រាយ លំនាំ ឬ គុណ ភាព នៃ ទស្សនៈ នៃ អធិបតេយ្យភាព របស់ ប្រជាជាតិ ពី អធិបតេយ្យភាព អត្តទត្តភាព ទៅ ជា អធិបតេយ្យភាព

[5] ពិភពលោកូបនីយកម្ម ; mondialisation ou globalisation។

ទទួលខុសត្រូវ។ ប្រជាជាតិ និមួយៗ ត្រូវ មាន ការទទួលខុសត្រូវ នៅ ចំពោះមុខ សព្វ អំពើ ដែល ខ្លួន បាន ប្រព្រឹត្ត ជា ចេតនា ក្តី ជា អចេតនា ក្តី ដែល នាំ ប៉ះពាល់ ដល់ សន្តិសុខ នៃ ពិភពលោក, សិទ្ធិមនុស្ស និង បរិស្ថាន នៃ មនុស្សជាតិ។ សញ្ញាណ នៃ ការទទួលខុសត្រូវ នេះឯង ដែល កំពុង លោះ នូវ ទស្សនៈ ថ្មី នៃ សណ្តាប់ធ្នាប់ នៃ ពិភពលោក។ អង្គការ អន្តរជាតិ មួយ ចំនួន បាន បង្កើត ឡើង ដូចយ៉ាង អង្គការ ការពារ ធាតុអាកាស ពិភពលោក cop21[6], ការពារ គ្រោះថ្នាក់ បរមាណូ (AIEA[7] ou IAEA)...។ល។ រូបភាព ទាំងឡាយ នេះ បង្ហាញ ថា ប្រជាជាតិ ជា ច្រើន មាន សតិសម្បជញ្ញៈរួម អំពី តម្លៃរួម នៃ មនុស្សជាតិ និង សំរាប់ បវរ អនាគត នៃ ពិភពលោក។ ដំណាច់ នៃ របប កុម្មុយនិស្ត នៅ អឺរ៉ុប នៅ ទស្សវត្សរ៍ ៩០ បើក ទស្សនវិស័យ សំរាប់ប្រជាជាតិ អោយអាច មាន ជម្រើស យក របប ដឹកនាំ ដែល ទុក ប្រជាពលរដ្ឋ ជា ម្ចាស់ នៃ អំណាចរដ្ឋ ទុក សេរីភាព នៃ បុគ្គល ជា អគ្គតម្លៃ នៃ មនុស្សលោក។ របប នេះ មាន ឈ្មោះ ថា លទ្ធិប្រជាធិបតេយ្យសេរី។ រួមសេចក្តីមក គេ អាច សន្និដ្ឋាន បាន ថា សណ្តាប់ធ្នាប់ ពិភពលោក បច្ចុប្បន្ន គឺ វា ស្ថិត នៅ ក្រោម ឥទ្ធិពល នៃ លទ្ធិប្រជាធិបតេយ្យសេរី ឈរ លើ គោលការ

[6] accord international sur le climat។
[7] L'Agence internationale de l'énergie atomique (AIEA)។

ណ៍ នៃ អធិបតេយ្យភាព ទទួលខុសត្រូវ របស់ ប្រជាជាតិនិមួយៗ នោះឯង។ តែ បញ្ហា នៃ សិទ្ធិមនុស្ស និង ការអនុវត្តន៍ នៃ លទ្ធិប្រជាធិបតេយ្យ នៅ មាន ចំណោទ សំរាប់ប្រជាជាតិ មួយ ចំនួន ដឹកនាំ ដោយ ជន ផ្តាច់ការ ឬគណបក្សនយោបាយ ទោល (តែមួយ) យល់ឃើញ ថា បញ្ហាទាំងពីរ នេះ ជា បញ្ហា ផ្ទៃក្នុង របស់ ប្រទេសខ្លួន ជាប្រទេស មាន អធិបតេយ្យភាព ដូច្នេះ មិនអាច មានប្រទេស ឬ អង្គការ ណាមួយ អាចជ្រៀតជ្រែកចូលបាននោះឡើយ។ តែ អ្នកដឹកនាំ ផ្តាច់ការ ទាំងនោះ បាន ជួបប្រទះនឹង បដិវត្តន៍ជាតិ កើតឡើង ដោយឯកឯង ពីសំណាក់ ប្រជាជន ដូច នៅ ប្រទេស Tunisie, Egypte, Lybie ជាអាថ៌។ បដិវត្តន៍ជាតិ ឬ បដិវត្តន៍ពណ៌ ដែល មានកើតឡើងនោះ បាន រំលំ របប ផ្តាច់ការ តែ បន្ត មក បានជួប នឹង ឧបសគ្គ ក្នុង ការបង្កើត របប លទ្ធិប្រជាធិបតេយ្យពហុបក្ស នាំ អោយ មាន កើត សង្គ្រាម ស៊ីវិល រវាង ភាគី នយោបាយ។ សួរ ថា វិបត្តិ ទាំង នោះ តើ វា អាច មានដំណោះស្រាយ នៅ ក្នុង ក្របខណ្ឌ សណ្តាប់ធ្នាប់ ពិភពលោក សព្វថ្ងៃ បាន ដែរ ឬទេ ?

គេ ដឹង ថា សព្វថ្ងៃ មាន មហាអំណាច បី សហរដ្ឋ អាមេរិក សាធារណរដ្ឋចិន ប្រជាមានិត និង សហព័ន្ធ រ៉ូស៊ី កំពុងប្រកួតប្រជែងគ្នា គ្រប់ វិស័យ ដើម្បី រក្សា ឬ ពង្រីក ឥទ្ធិពល របស់ ខ្លួន នៅ ក្នុង ពិភពលោក ដែល នាំ អោយ

មាន ការប្រែផ្លាស់ សណ្ដាប់ធ្នាប់ ពិភពលោក ព្រោះ មហាអំណាច ទាំង បី នោះ មាន ទស្សនៈ មនោគមវិជ្ជា ខុសៗគ្នា ដូច ធ្លាប់ មាន នៅ ក្នុង សង្គ្រាម ត្រជាក់ ក្រោយ ពីសង្គ្រាម លោក លើក ទី២ មក។ តែ គេ អាច សួរ ជា សំណួរថា តើ សហរដ្ឋ អាមេរិក (ស.រ.អ.) បច្ចុប្បន្ន នៅ ចង់ ថែរក្សា តួនាទី ខ្លួន ជា អ្នកការពារ លទ្ធិប្រជាធិបតេយ្យសេរី នៅ ក្នុង ពិភពលោក ទៀតឬ ឬ គ្រាន់ តែ ថែរក្សា ឬ ការពារ ដំបន់ ទាំងឡាយ នៅ ក្រោម ឥទ្ធិពល របស់ ខ្លួន ក្រោយ ពី សង្គ្រាម លោក លើក ទី២ មក ? គេ ដឹង ថា ប្រទេស ចិន សព្វថ្ងៃ ក្លាយ ជា មហាអំណាច សេដ្ឋកិច្ចមួយ, អាច ប្រឈមមុខ នឹង សហរដ្ឋអាមេរិក, កំពុង វាតឥទ្ធិពល សេដ្ឋកិច្ចខ្លួន នៅ ដំបន់ អាហ្វ្រិក អាស៊ី និង អឺរ៉ុប ហើយ មាន មហិច្ឆិតា ពោលអះអាង ថា ចិន កំពុង ធ្វើ ប្រទេស ខ្លួន អោយក្លាយ ជា មហាអំណាច យោធា[8] ជា ពិសេស នៅ ក្នុង វិស័យ កងទ័ព ជើងទឹក ដូច នៅ ពេល ថ្មីៗ នេះ ចិន កំពុង សង់ នាវា ដឹក យន្តហោះ មួយ គ្រឿង ទៀត (នាវាទី២) ដើម្បី បញ្ជាក់ នូវ មហិច្ឆិតា នោះ ដូចយ៉ាង ជម្លោះ ចិន ជា មួយ នឹង ប្រទេស ជប៉ុន ហ្វីលីពិន វៀតណាម និង តៃវ៉ាន់ នៅ ដំបន់ សមុទ្រ ចិន ខាងត្បូង។ នៅ ឆ្នាំ ២០១៥ ចិន បង្កើត កោះសិប្បនិម្មិត ជា ជួរថ្ម

[8] ថវិកាយោធាចិន ឡើង ១០% នៅ ឆ្នាំ ២០១៥ គឺ មាន ចំនួន លុយ ជាង ១៤៥ កោដិ ដែល នឹង ដេញទាន់ ក្នុងពេលឆាប់ នៃ ថវិកា យោធា សមគម អឺរ៉ុប។

ប៉ប្រះទឹក (Fiery Cross) ហើយ ដំឡើង ចង្កៀងបញ្ចាំងផ្លូវ សមុទ្រ និង សញ្ញានាំផ្លូវនាវា ដើម្បី ធ្វើនាវាចរណ៍ នាំ អោយ វៀតណាម មាន ការក្តៅក្រហាយ។ មិន តែ ប៉ុណ្ណោះ ចិន សង់ កំពែងខ្សាច់ ដ៏ធំ បង្កើត មូលដ្ឋាន កងទ័ពនាវា រួច អោយ ផ្ទាំងផ្ទៃសមុទ្រ ធ្វើ ល្បាត ជា រឿយៗ និង ប្រដិត អោយ មាន បេសកកម្ម វិទ្យាសាស្ត្រ ក្នុង គោលដៅ ដើម្បី ពោលអះអាង នូវ អធិបតេយ្យភាព របស់ចិន នៅ ដំបន់ នោះ។ នៅ ចំពោះមុខ ការសម្តែង កម្លាំង នោះ វៀតណាម គ្មាន អ្វី តទល់ នោះឡើយ ក្រៅតែ តាំង យោធភូមិ អកម្ម ជា មធ្យោបាយ ការពារ ជា និមិត្តរូប តែប៉ុណ្ណោះ។ តែ ចំពោះ ជម្លោះ ចិន ជា មួយ ប្រទេស ហ្វីលីពិន និង វៀតណាម ចិន គេ ប្រើ នយោបាយទូត របៀប សម្លុតផង លួងលោមផង ដែល ចិនបុរាណ គេ តែងយកមក អនុវត្ត នៅ ចំពោះ គូរសត្រូវ របស់គេ។

មហិច្ឆាតា ចិន ក្នុង វិស័យ យោធា គឺ ប្រែផ្លាស់ លក្ខណៈ កងទ័ព ចិន ពី កងទ័ព ការពារជាតិ អោយ ទៅ ជា កងទ័ព អាច មាន សក្តានុពល អាច ធ្វើ ប្រតិបត្តិការ យោធា នៅក្រៅប្រទេស បាន។

ចំណែក ខាង សហព័ន្ធ រ៉ូស៊ី វិញ នៅ ក្រោម ការដឹកនាំ របស់ លោក ពូទិន មាន នយោបាយ នៅ ក្នុង បរិបទ យុទ្ធសាស្ត្រថ្មី គឺ បំណង ចង់ អោយ មហាអំណាច ដទៃទៀត

ទទួល ស្គាល់ ខ្លួន ជា មហាអំណាច ពេញលេញ មួយ។ គោល ដៅ របស់ លោក ពូទីន គឺ សំដៅ ដណ្តើមយកវិញ នូវ ទឹក ដី ណា ដែល មាន ប្រជាជន និយាយ ភាសា រ៉ូស៊ី និង ទឹក ដី ប្រវត្តិសាស្ត្រ របស់ ប្រជាជាតិ រ៉ូស៊ី ដូច យ៉ាង ដែនដី Crimée, Abkhazie, Ossétie du Sud, នៅ Donbass, Transnistrie ឬ ប្រទេស Baltes ដើម្បី បង្កើត រដ្ឋ-ប្រជាជាតិ (Etat-nation) មួយ មាន ភាពមាំមួន។ នៅ ចំពោះមុខ អង្គការ OTAN យុទ្ធសាស្ត្រ រ៉ូស៊ី គឺ ការសម្តែង ម្តងជា សកម្មភាព គ្រាន់តែ ការពារ ប្រយោជន៍រ៉ូស៊ី ម្តងជា សកម្មភាព វាយលុក ស្វែង រក ប្រយោជន៍ថ្មី ដែល នាំ អោយ មស្ទីមប្រទេស រស់នៅ ក្នុង ភាពទេទើរ ជា អតិបរមា។

សហរដ្ឋ អាមេរិក មាន ស្ថានភាព យុទ្ធសាស្ត្រ លើសគេ នៅ សមុទ្រចិន ទាំងពីរ ដោយ ខ្លួន បាន ឈ្នះ ចំបាំង ប្រទេស ជប៉ុន នៅ ឆ្នាំ ១៩៤៥។ នៅ ក្នុង ដំបន់ នោះ ស.រ.អ. មាន បណ្តាញ មូលដ្ឋាន យោធា ជាច្រើន ដូចយ៉ាង នៅ កោះ Guam, នៅ ប្រទេស ជប៉ុន (Okinawa), កោះ តៃវ៉ាន់, ប្រទេស កូរ៉េខាងត្បូង, ប្រទេស ហ្វីលីពិន និង មាន ប្រទេស វៀតណាម ជា សម្ពន្ធមិត្ត។ ស.រ.អ ពង្រីក យុទ្ធសាស្ត្រ ការពារ ដំបន់ អាស៊ី បាស៊ីហ្វិក នៅ ចំពោះមុខ យុទ្ធសាស្ត្រចិន ដែល នាំ បង្កើន ភាពតានតឹង រវាង ប្រទេស ទាំងពីរ នាពេលបច្ចុប្បន្ន នេះ។ នៅ អឺរ៉ុបយុទ្ធសាស្ត្រ របស់ស.រ.អ. មាន ស្ថានភាពដដែល គឺ ពង្រឹង OTAN ដើម្បី ប្រឈរ

មុខ នឹង យុទ្ធសាស្ត្រ រ៉ូស៊ី។ តើ ស.រ.អ. នៅតែបន្ត គោលដៅ នៃ នយោបាយ ការបររទេស បង្កបង្កើត ប្រជាជាតិ អនុវត្ត លទ្ធិប្រជាធិបតេយ្យ នៅក្នុង សាកលលោក ? ចំពោះ ស.រ.អ. ការប្តូរ របបផ្តាច់ការ គឺ មិនមែន គ្រាន់តែ ជាមធ្យោបាយ សំរាប់ដោះស្រាយ នយោបាយផ្ទៃក្នុង ក្នុងប្រទេសមួយ គឺ វា ជា គុណធម៌ សំរាប់ ប្រជាពលរដ្ឋ ដែលរំដោះ ខ្លួន ចេញ ពី របប ផ្តាច់ការ ក្នុង នាម សេរីភាព។

គេ សង្កេតឃើញ ថា មហាអំណាច ទាំងបីនេះ សព្វថ្ងៃ កំពុង រចនា សណ្តាប់ធ្នាប់ ពិភពលោកថ្មី ស្របតាម អត្ថប្រយោជន៍ របស់ ខ្លួន រៀងៗខ្លួន ជួនកាល គេ នាំ គ្នា គោរព គោលការណ៍ ដើម្បី វៀរចាក សង្គ្រាម រវាង ប្រជាជាតិ នឹង ប្រជាជាតិ ដោយ គោរព ទៅវិញ ទៅមក ដល់ អធិបតេយ្យភាព នៃ ប្រជាជាតិ និមួយៗ ជួនកាល គេ យក នយោបាយប្រាកដនិយម (realpolitik) សំរាប់ រកចែក ប្រយោជន៍គ្នា។ ជួនកាល គេ យក អង្គការ សហប្រជាជាតិ ជា ឧបករណ៍ សំរាប់ ដោះស្រាយ ជម្លោះ អន្តរជាតិ ឬ សង្គ្រាម ស៊ីវិល ឬ សង្គ្រាម ដំបន់។ តែ អ្នក ទាំង បី មាន ទស្សនៈរួមមួយ គឺ គេ មាន ជំនឿ ជានិច្ច ថា កម្លាំងទ័ព ជាមធ្យោបាយ នយោបាយ សំរាប់បិទនុយ (amorcer) នៃ ការចរចា។ ហេតុនេះឯង បាន ជា គេ នៅតែបន្ត ការប្រកួតប្រជែងគ្នា បង្កបង្កើត សព្វាវុធ យោធា ទំនើប និង មាន ប្រសិទ្ធិភាព បម្រុងទុក ជា មុន សំរាប់ ធ្វើ ស

ង្គ្រាម ដែល វា នៅ តែ មាន ជានិច្ច នៅ ក្នុង ពិភពលោក សព្វថ្ងៃ។ វាជា សង្គ្រាម មាន រូបភាព តូចៗ ពិត តែ ប្រើ សព្វាវុធ ទំនើប របស់ មហាអំណាច ដែល នាំ អោយ មាន ឧបទ្ទវហេតុ (désastre) ដល់ មនុស្សជាតិ ព្រោះ នៅ ក្នុង សង្គ្រាម កូនកាត់ (guerre hybride)[9] ឬ កូន សង្គ្រាម នានា មាន កើត ឡើង នៅ គ្រប់ ដំបន់ ការប្រើ អំពើ ហិង្សា វា ទៅ ជា ទម្លាប់ ធម្មតា រវាង គូរសត្រូវ។ សួរ ថា តើ លទ្ធិប្រជាធិបតេយ្យ នៅ ក្នុង ពិភពលោក ប្រកប ដោយ អនិរភ័យ សព្វថ្ងៃ វា មាន មហាអំណាច ឬ អង្គការ ណា មួយ ជា អ្នក ធានា ការពារ វា ?

## សន្តិភាព

សណ្តាប់ធ្នាប់ពិភពលោក គឺជា មធ្យោបាយ សំរាប់ការពារ សន្តិភាព។ ចំពោះ ពួកអ្នកតាំងខ្លួន ដោយខ្លួនឯង ជា អ្នកប្រាកដនិយម គេ មាន ទស្សនៈ ថា សន្តិភាព វាគ្រាន់ តែជា ការតថ្លៃគ្នាធម្មតា បញ្ជាក់អំពី ការទាក់ទង នៃ កម្លាំង មាន សមតា តិចឬច្រើន សំរាប់ដោះស្រាយ ជម្លោះ រវាង គូសត្រូវ។ ទស្សនៈនេះ វាបង្ហាញ នូវ រូបភាព នៃ ពួក អ្នកការទូត ជូន ជា មនុស្សភោរភាវ និយាយពាក្យ ប្រិមប្រិយ ដើម្បី រកដំណោះស្រាយ នៃ ជម្លោះ, ជូនជា

[9] សង្គ្រាម កូននកាត់ (guerre hybride); ជា សង្គ្រាម មាន ភាព ជួន ជា សង្គ្រាម និយ័ត (ទៀងទាត់) (guerre régulière) ជួន ជា សង្គ្រាម អនិយ័ត (guerre irrégulière)។

ឈ្មួញលក់ព្រាំ ទទួលបន្ទុក លក់ចុះថ្លៃ នៃ ប្រយោជន៏ជាតិ។ ចំពោះ ពួកអ្នកគំនិតនិយម វិញ សន្តិភាព ឋិតនៅលើ វិធានមួយ សំរាប់ គូវិវាទ យកវាមកអនុវត្ត ដើម្បីដោះស្រាយ វិបត្តិ។ សន្តិភាព បែបនេះ វាប្រព្រឹត្តទៅ ដូចជា ម៉ាស៊ិន ដែល តម្រូវអោយមាន ការថែទាំ យូរៗម្តង, តែភាគច្រើន វា អាច ថែរក្សាខ្លួនវា ដោយខ្លួនឯង។ ក្នុង ទស្សនៈនេះ គឺ យល់ឃើញថា បើម៉ាស៊ិន វាខូច ត្រូវនាំគ្នា អត់ធ្មត់សិន ហើយនាំគ្នា ស្រម័យ ថា ថ្ងៃស្អែក នឹងមាន សន្តិភាព។ តែ សន្តិភាព វាមិនមែន ជា សម្ភីភោរភារ នៃ អ្នកការទូតក៏មិនមែន ជា ម៉ាស៊ិន នោះដែរ វាជា មហាមហិច្ឆិតា នៃ មនុស្សជាតិបច្ចុប្បន្ន ដែល ជា កាលសម័យ ពោលអះអាងនូវជោគជ័យ នៃ សន្តិភាព លើ សង្គ្រាម ដែលជា សេចក្តីប្រាថ្នាដាច់ខាត របស់ បុព្វរជន ពិភពលោក និង បច្ចុប្បន្ន មួយចំនួន ទាំង ស៊ីវិល និង យោធា ធ្វើការសំភីរួមគ្នា ជាប្រក្រតី ដើម្បី សន្តិភាព គឺ វៀចាក នូវ អ្វីៗដែលអាក្រក់បំផុត ក្នុង គោលបំណង កសាង អនាគត ដ៏បវរ ដល់ មនុស្សជាតិ។ ដូច្នេះ ការកសាង សន្តិភាព គឺជាកិច្ចការ នៃ មនុស្សលោក។ នរទំហំ (dimension humaine) នេះឯង ដែលសម្រេចបាន នូវ សេចក្តីប្រាថ្នា ព្រោះវាអាចអោយ យល់ដឹង អំពី ទុព្វលភាព ប៉ុនគ្នានឹង ការមានជោគជ័យ។ ដ្បិត ជា ផលា នៃ កិច្ចការលំបាកអស់ពេលយូរមួយ សន្តិភាព វានាំបង្កើត នូវ ទម្លាប់, ប្រពៃណី, ជំនឿ

ដែល រក្សារ៉ាប់រង នូវ ការបន្តកិច្ចការលំបាកនោះ រហូតទៅជាកិច្ចការ ជា ទម្លាប់ធ្វើដដែលៗ ដែលជា ទម្លាប់ជៀសមិនរួច ហេតុដូច្នេះឯង ត្រូវមានការប្រុងប្រយ័ត្នជានិច្ច ក្នុង ប្រតិបត្តិការ ស្វែង ឬ រក្សា សន្តិភាព ដើម្បីជៀសវៀង នូវ ការពិសោធន៏អសោច យកវាមក អនុវត្តដោយគ្មានធ្វើវិភាគ រក ល្អអាក្រក់។ នយោបាយ សន្តិភាពមិនដូចជា នយោបាយដទៃទៀតនោះឡើយ ព្រោះ រូបធាតុវា គឺមានតែ ព្រលឹងស្មារតី នៃ មនុស្សា ដូចយ៉ាង បើនៅពេលណា មនុស្ស មាន ក្រោធ ក្នុងចិត្ត គឺកំហឹងនោះវាអាចនឹងបំផ្លាញ ស្មារតី សន្តិភាព បានយ៉ាង ងាយបំផុត។ ហេតុដូច្នេះ ដើម្បី ទប់ទល់នឹង ព្រលឹងស្មារតីអវិជ្ជមានជាសត្រូវនឹងសន្តិភាព ការស្វែង ឬ រក្សា សន្តិភាព ត្រូវមាន គោលវិធី, មធ្យោបាយ និង គោលដៅ ច្បាស់លាស់ និង អាចវាស់វែងបាន។ សន្តិភាព ស្ថិតនៅក្នុងពាក្យស្រពិចស្រពិល និង វាចាភណ្ឌការ (paroles belliqueuses) វាគ្មានទម្ងន់ បន្តិចបន្តួចអ្វីឡើយ សំរាប់ព្រលឹងស្មារតី នៃ សន្តិភាព។

សន្តិភាព គឺជា ស្នាដៃ នៃ មនុស្សា ដោយ មនុស្សា និង ដើម្បី មនុស្សា ព្រោះ អគ្គគោលដៅ របស់វា គឺ វាសនារួមរបស់មនុស្សយើង ដូច្នេះ វាជា អំពើ នៃ ឆន្ទៈ របស់មនុស្សមិនមែន ជា អគ្គទាន (ទានដ៏ប្រសើរ) របស់អាទិទេពនោះឡើយ។ ជនណា ដែលមានជំនឿថា ខ្លួនជាអ្នក ផ្តល់

សន្តិភាព អោយ អ្នកដទៃ គឺ ច្បាស់ជាផ្តល់ នូវ សន្តិភាព អសោច ជាពុំខាន ព្រោះ សន្តិភាព ជាស្នាដៃរួម នៅក្នុង ព្រលឹងស្មារតី នៃ សាមគ្គីភាព។

## ខណ្ឌសីមាថ្មី នៃ ពិភពលោក

សម័យ Internet កំណត់ ផែនដីថ្មី (nouvel espace) នៃ ពិភពលោក ដែល ជា ផែនដី អសម្ភារៈ។ គេអាចទុក Internet ជា អធិពិភពលោកូបនីយកម្ម[10] ព្រោះវា ជា អង្គការ ឡូស៊ិក (organisation logique) តែគ្មាន ភូមិសាស្ត្រ ជាពិសេស វា អង្គការ មានជម្រៅជ្រៅ នៃនយោបាយ ព្រោះ ពួកយក្ស Internet ដូចយ៉ាង Google, Apple, Microsoft, Facebook, Twitter សុទ្ធតែមាន ផែនការ នយោបាយ ហើយ គេឃើញមាន ពួក គំនិតហួសវិស័យនិយម និង សកម្មជន ការពារ ចក្ខុវិស័យ Internet ជា សង្គមស៊ីវិល ពូតដៃគ្នា ប្រឆាំងនឹង អំណាចរដ្ឋ។ ពលរដ្ឋ ពិភពលោកសព្វថ្ងៃ ប្រើបណ្តាញ Internet ប្តូរ វិស័យមតិគ្នា ជាអចិន្ត្រៃយ៍ បង្កើតជា លទ្ធិប្រជាធិបតេយ្យ សហការ និង ក្បួនដោះស្រាយ (algorithmique) ដែល សព្វគ្នា អាចនឹង មាន សមភាព ធានា ដោយ រចនាសម្ព័ន្ធ វិមជ្ឈការ នៃ បណ្តាញ និង ភាពនៅក្រៅដែនដី (extra-territorialité)

[10] អធិពិភពលោកូបនីយកម្ម ; surmondialisation.

ដែលជាការរួចចាក តិចច្រើនក្តី ពីច្បាប់រដ្ឋនិមួយៗ នោះបី ការរួចចាកនោះ វានៅមាន ន័យខុសគ្នាបន្តិចបន្តួច ដែលសព្វគ្នា ត្រូវលើកយកមកបញ្ជាក់។ ដូច្នេះ គេអាចទុក Internet តាម ធម្មជាតិ នៃផែនដី របស់វា ជាសេរីភាពឯកត្តភូត។

នៅក្នុងផែនដី នៃ សេរីភាព ឯកត្តភូត នោះ រដ្ឋនិមួយទទួលស្គាល់វា តែ ខំត្រួតពិនិត្យ, ទប់ ឬ បន្ទោស វា ទៅតាមការប្រែប្រួលនៃ បុរិមា (préférence) របស់ខ្លួន, ដូចមាន ការអំពាវនាវ អោយមាន អ៊ិនធឺណិអារ្យៈ, អ៊ិនធឺណិត្រឹមត្រូវ, អ៊ិនធឺណិអនាម័យ ឬ អ៊ិនធឺណិបរិសុទ្ធ[11]។ នៅក្នុងប្រទេស ដឹកនាំដោយ របបសិទ្ធិអំណាច អាជ្ញាធរប្រឆាំងដាច់ខាតនឹង សេរីភាព ឯកត្តភូត នោះ ហើយ គេត្រួតពិនិត្យវា ក្នុងនាម អ៊ិនធឺណិអធិបតេយ្យ។ តែ នៅក្នុងប្រទេស ប្រជាធិបតេយ្យសេរី ជួន ក៏ឃើញមាន ច្បាប់តឹងរឹង ប្រឆាំងនឹង ទម្រង់ នៃ សេរីភាព ណាមួយ ដែលជា ទុរុបយោគ (ការបំពាន) និង ភាពគ្មានមានសណ្តាប់ធ្នាប់។ តែត្រូវដឹងថា សណ្តាប់ធ្នាប់ Westphalien និង សណ្តាប់ធ្នាប់ ឆ្លងប្រទេស (transnational) វាប្រឆាំងគ្នានៅឡើយ ម្ខាងក្នុងនាម សេរីភាព ម្ខាងទៀត ក្នុងនាម អធិបតេយ្យជាតិ៕

[11] Internet civilisé (France), Internet sain (Chine), Internet hygiénique (USA), Internet pur (Iran).